ឆ្នាំ ទី៥ លេខ ៥ ថ្ងៃ ១៨ ខែ កុម្ភៈ ឆ្នាំ ២០០១ រាជកិច្ច ទំព័រ ៣៤៥

# ព្រះរាជក្រឹត្យ នស.រកត.០២០១.០៣០

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាព ពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .-**

ត្រូវបានបង្កើតសញ្ញារាជរដ្ឋាភិបាល សំរាប់ប្រើប្រាស់ជាផ្លូវការរបស់រដ្ឋ ។

**មាត្រា ២ .-**

សញ្ញារាជរដ្ឋាភិបាល ដែលមានរូបភាព និងខ្នាត ដូចក្នុងឧបសម្ព័ន្ធភ្ជាប់ ត្រូវបានកំណត់ដូចតទៅ :-

- មានរាងពងក្រពើ និងមានពណ៌មាស
- ទទឹងប្រវែង 3>4 នៃបណ្តោយ
- នៅខាងក្រោម ចំកណ្តាលមានក្បាច់ដកចន្ទន៍ និងមានកួរស្រូវពីរកួរកោងរាងស្វែងក្របី ដែលតំណាងឱ្យប្រជារាស្ត្រ

Media from www.moj.gov.kh

16/05/2021



- មានជើងពានមួយទ្រព្រះខ័ននៅពីលើកួរស្រូវ ដែលតំណាងឱ្យអំណាចនីតិប្រតិបត្តិ
- លើព្រះខ័នមានមកុដរាជ តំណាងឱ្យព្រះរាជបល្ល័ង្គ និងនៅលើមកុដរាជមានកាំរស្មី១៥កាំ ។

**មាត្រា ៣ ..**

សញ្ញារាជរដ្ឋាភិបាល សំរាប់ប្រើប្រាស់ដូចខាងក្រោមនេះ :-

- ដាក់នៅកន្លែងធ្វើការរបស់រាជរដ្ឋាភិបាល
- ធ្វើប្រទីបរបស់រាជរដ្ឋាភិបាល
- បំពាក់នៅលើអាវរបស់សមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការ
- ដាក់នៅលើក្បាលលិខិតប្រើប្រាស់ជាផ្លូវការ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

**មាត្រា ៤ ..** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

Media from www.moj.gov.kh

16/05/2021



ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យ លេខ នស/រកត/០២០១/០៣០
ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពី
សញ្ញារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០១ ០៣០
ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពី
សញ្ញារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

សញ្ញារាជរដ្ឋាភិបាល

Media from www.moj.gov.kh